## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ



ELECTRICITE DU CAMBODGE

**អគ្គិសនីកម្ពុជា**

លេខ: ០១៦៦ អសដណ.អក.បប

# សេចក្តីជូនដំណឹង
## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជាត្រូវការជ្រើសរើស**បុគ្គលិក** សរុបចំនួន០២រូប ដើម្បីចូលបម្រើការងារនៅតាមបណ្តាអគ្គិសនីខេត្ត ដូចខាងក្រោម :

*- **លក្ខណៈសម្បត្តិបេក្ខជន** :

**១- ភ្នាក់ងារត្រួតពិនិត្យចលនានាឡិកាស្ទង់និងការងារទូទៅ** នៅ**អគ្គិសនីសៀមរាប** ចំនួន០១រូប :

- បេក្ខជនភេទប្រុស មានអាយុចាប់ពី១៨ឆ្នាំ ដល់ ៣៥ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.I.១ ក្នុងពេលសាកល្បងការងារ០៣ខែ ទទួលបាន៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សាវិស្វករអគ្គិសនីឡើងទៅ

**២- បុគ្គលិកបច្ចេកទេសGIS** នៅ**អគ្គិសនីកំពង់ស្ពឺ** ចំនួន០១រូប :

- បេក្ខជនទាំងពីរភេទ មានអាយុចាប់ពី១៨ឆ្នាំ ដល់ ៣៥ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ០៣ខែ ទទួលបាន៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សាសញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនីឡើងទៅ

*- **ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជាបេក្ខជនត្រូវទាញយក(Download) ដោយផ្ទាល់ពីក្នុងគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុចព័ត៌មានវិជ្ជាជីវៈ ដោយចុចលើពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជា។**

*- **បេក្ខជនត្រូវបំពេញពាក្យសុំចូលបម្រើការងារ និងត្រូវអញ្ជើញមកដាក់ពាក្យប្រឡងដោយផ្ទាល់ខ្លួន និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនច្បាប់ដើមមកជាមួយ។ ករណីបេក្ខជនមិនបានអញ្ជើញមកដាក់ពាក្យដោយផ្ទាល់ទេ អគ្គិសនីកម្ពុជាមិនទទួលពាក្យជូនឡើយ។**

*- **បេក្ខជនដាក់ពាក្យត្រូវពាក់ម៉ាស់ និងរក្សាគម្លាតសុវត្ថិភាពឲ្យបានត្រឹមត្រូវ។**

*- **បេក្ខជនត្រូវមកដាក់ពាក្យ និងភ្ជាប់មកជាមួយនូវ** :

| | |
|---|---|
| - ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារ នៅអគ្គិសនីកម្ពុជា | ចំនួន០១ច្បាប់ |
| - ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ | ចំនួន០១ច្បាប់ |
| - កិច្ចសន្យា សម្រាប់បំពេញពាក្យសុំចូលបម្រើការងារ និងកិច្ចសន្យាការងារ | ចំនួន០១ច្បាប់ |
| - សលាកប័ត្របេក្ខជន | ចំនួន០១ច្បាប់ |
| - ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ | ចំនួន០១ច្បាប់ |
| - តារាងពិន្ទុ(TRANSCRIPT) | ចំនួន០១ច្បាប់ |
| - ច្បាប់ដើម និងច្បាប់ចម្លងនៃអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន | ចំនួន០១ច្បាប់ |

*- **ចំពោះបែបបទមួយចំនួនទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធI នៃលក្ខន្តិកៈបុគ្គលិកអគ្គិសនីកម្ពុជា បេក្ខជនប្រឡងជាប់ មានកាតព្វកិច្ចបំពេញបន្ថែម។**

*- **ទីកន្លែងទទួលពាក្យ** : **នៅកីឡដ្ឋានបាល់ទាត់អគ្គិសនីកម្ពុជា (អតីតរោងចក្រអគ្គិសនីទី៤)។**

ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣ រៀងរាល់ថ្ងៃធ្វើការ

- **ពេលព្រឹក** ចាប់ពីម៉ោង០៨:០០ ដល់ម៉ោង១១:៣០ **ពេលល្ងាច** ចាប់ពីម៉ោង១៤:០០ ដល់ម៉ោង១៧:០០

*- **ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

ថ្ងៃច័ន្ទ ៣រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣

**ជ. រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកអគ្គិសនីកម្ពុជា**
**អគ្គនាយករង**

ELECTRICITE DU CAMBODGE

**អេង_គន្ធា**

**បញ្ជាក់**

- សេចក្តីជូនដំណឹងនេះ ធ្វើការផ្សព្វផ្សាយជាផ្លូវការតាមរយៈគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុច " ព័ត៌មានវិជ្ជាជីវៈ " ។